# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ព្រះសង្ឃព្រះពុទ្ធសាសនាក្រៅពីប្រទានធម៌ទេសនា ព្រះអង្គបានជួយសង្គ្រោះដល់ខ្មែរដែលទទួលរងគ្រោះដោយវត្ថុសម្ភារៈទៀតផង ។

**Website: www.hoksavann.org**

ថ្ងៃទី២២ មករា ២០១០



ពុទ្ធភាសិតថា សព្វទានំ ធម្មទានំ ជិនាតិ ប្រែថាធម្មទានឈ្នះអស់ទានទាំងពួង ។ ពាក្យនេះមានអត្ថន័យថា ការឲ្យវត្ថុផ្សេងៗដូចជាការឲ្យបាយទឹកនំចំណី សំលៀកបំពាក់ ទីលំនៅ ថ្នាំកែរោគជាដើម មិនប្រសើរជាងការឲ្យព្រះធម៌ គឺការប្រាប់មធ្យោបាយល្អ មធ្យោបាយត្រូវ ឆ្ពោះទៅរកសេចក្តីសុខចំរើនឡើយ ។ ឧទាហរណ៍ការឲ្យផ្លែស្វាយមួយ គេទទួលទានតែម្តងក៏អស់ទៅ ប៉ុន្តែគេមិនឲ្យផ្លែស្វាយទេ គេឲ្យគ្រាប់ស្វាយ ហើយប្រាប់មធ្យោបាយឲ្យយកគ្រាប់នោះទៅដាំដាក់ជីរស្រោចទឹកថែទាំរហូតដុះជាដើមបែកជាមែកបញ្ចេញជាផ្កាផ្លែ គេបេះរាល់ឆ្នាំ ។ យ៉ាងណាមិញ ព្រះធម៌ដែលព្រះពុទ្ធសំដែង បានបង្ហាញនូវមាគ៌ាឆ្ពោះទៅរកសេចក្តីសុខចំរើន ដល់ពុទ្ធសាសនិកជនខ្មែរសំរាប់យកទៅប្រតិបត្តិ ។ ជីវិតក្នុងបច្ចុប្បន្នត្រូវខំសិក្សារៀនសូត្រ ខំប្រឹងប្រកបរបរចិញ្ចឹមជីវិតប្រកបដោយធម៌ បណ្តុះគុណធម៌មានសីលធម៌ជាដើមឲ្យបានប្រសើរថ្លៃថ្លា ។ ព្រះធម៌បានបង្ហាញផ្លូវទៅកាន់ការរំលត់ទុក្ខទាំងអស់គឺព្រះនិព្វន បានដល់មគ្គគឺផ្លូវប្រតិបត្តិប្រកបដោយអង្គ៨ បើរួមឲ្យខ្លី បានដល់ទានសីលភាវនា ឬសីលសមាធិបញ្ញា ។ ការសិក្សាឲ្យយល់ច្បាស់លាស់អំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអាទិទេពទីមួយរបស់ព្រះពុទ្ធសាសនា ដើម្បីប្រតិបត្តិឲ្យបានត្រឹមត្រូវក្នុងនាមពុទ្ធសាសនិកជន ។ ពុទ្ធសាសនាបង្ហាញព្រះធម៌ គឺមធ្យោបាយរំលត់ទុក្ខ (ធម្មទីបា) ចំណែកពុទ្ធសាសនិកជនបានដើរតាម គឺប្រតិបត្តិឬអនុវត្តដោយខ្លួនឯង (អត្តទីបា) ។ ព្រះធម៌នៃព្រះពុទ្ធ បានក្លាយជាព្រលឹងវិញ្ញាណដក់ជាប់ក្នុងសន្តានចិត្តនៃពុទ្ធសាសនិកជនខ្មែរគ្រប់រូប ។

ព្រះសង្ឃព្រះពុទ្ធសាសនា ក្រៅពីប្រោសប្រទានព្រះធម៌ដល់ពុទ្ធបរិស័ទ ព្រះអង្គខ្លះបានផ្តល់អំណោយដោយសម្ភារៈ ឬជាប្រាក់កាសដល់ជនរងគ្រោះដោយគ្រោះធម្មជាតិ ដូចជាត្រូវខ្យល់ព្យុះ ត្រូវទឹកជំនន់ ធ្វើឲ្យខូចខាតផ្ទះសំបែង និងដល់ជនកំព្រាអនាថា ដល់ជនពិការ ដោយទឹកចិត្តអាណិតអាសូរ ។ អំណោយទាំងនោះបានមកពីពុទ្ធបរិស័ទប្រគេនព្រះអង្គផ្ទាល់ ឬបានមកពីសប្បុរសជនតាមការណែនាំរបស់ព្រះអង្គ ដើម្បីបានវត្ថុទាំងនោះយកទៅជួយសង្គ្រោះអ្នករងគ្រោះ ។ មិនតែប៉ុណ្ណោះ មានព្រះសង្ឃខ្លះដែលមានសមត្ថភាពនិងមានលទ្ធភាព បានជួយចិញ្ចឹមក្មេងកំព្រាអនាថាគ្មានទីពឹងទៀតផង ។ មួយទៀត នៅតាមវត្តអារាមនានា នៅស្រុកស្រែចំការនិងនៅទីក្រុង តែងតែមានកុមារនិងយុវជនស្នាក់នៅ ដើម្បីសិក្សារៀនសូត្រក្រោមការឧបត្ថម្ភពីព្រះសង្ឃ ។ គុណសប្បុរសធម៌របស់ព្រះសង្ឃនេះបញ្ជាក់ថា ទោះបីព្រះអង្គមិនបានរកស៊ីធ្វើការដូចជាគ្រហស្ថ (ព្រោះវិន័យមិនអនុញ្ញាត) ក៏ព្រះអង្គខំប្រឹងប្រែងបិណ្ឌបាត្រពីសទ្ធាពុទ្ធបរិស័ទយកមកជួយសង្គ្រោះចំពោះអ្នករងគ្រោះ ឬកុមារកំព្រាគ្មានទីពឹងដែរ ។ ធម៌សង្គ្រោះនេះព្រះពុទ្ធសំដែងថា ជាសង្គហធម៌ គឺការធ្វើទានដោយសេចក្តីសង្គ្រោះចំពោះអ្នកមានទុក្ខ ដោយសេចក្តីករុណាគឺការអាណិតអាសូរ ។ នេះជាសង្គហធម៌ផ្នែកទីពីរ បន្ទាប់ពីព្រះអង្គបានប្រទានធម៌ទេសនាបណ្តុះគុណធម៌ដល់ពុទ្ធបរិស័ទខ្មែរជាផ្នែកទីមួយមក ។ មានព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរខ្លះ បានផ្តល់អំណោយជាសម្ភារៈ ឬជាបច្ច័យដល់កាកបាតក្រហមខ្មែរ ឲ្យយកទៅចែកជនជាតិខ្មែរដែលរងគ្រោះនិងអ្នកក្រីក្រទៀតផង ។

ព្រះសកម្មភាពដ៏ឧត្តុងឧត្តមរបស់ព្រះសង្ឃចំពោះសង្គមខ្មែរនេះ ជាចម្លើយតបទៅនឹងគ្រិស្តសាសនា ដែលបានផ្សាយអួតអាងតាមវិទ្យុនៅភ្នំពេញប្រទេសកម្ពុជាថា មានតែសាសនាខ្លួនទេដែលអាចចែកអំណោយដល់ជនជាតិខ្មែរក្រីក្រ ។ សំដីអួតអាងនោះបានត្រូវរដ្ឋមន្ត្រីក្រសួងពត៌មាននៃរាជរដ្ឋាភិបាលខ្មែរ ធ្វើលិខិតព្រមានទៅគ្រប់វិទ្យុនិងទូរទស្សន៍ កុំឲ្យនិយាយប៉ះពាល់ដល់ព្រះពុទ្ធសាសនាដូចគ្រិស្តសាសនានេះ ព្រោះព្រះសង្ឃព្រះពុទ្ធសាសនាក៏មានចែកអំណោយជាប្រពៃណីជាយូរមកហើយ ។ ដោយមានសកម្មភាពបែបនេះ យើងសូមអនុញ្ញាតធ្វើការវិភាគអំពីសកម្មភាពរបស់អ្នកផ្សាយគ្រិស្តសាសនា ដែលចែកអំណោយដល់ជនជាតិខ្មែរនេះ តើធ្វើឡើងដោយសុទ្ធចិត្ត ឬដោយបំណងយ៉ាងណា ? បើអ្នកផ្សាយគ្រិស្តសាសនានេះចែកអំណោយដោយមានបំណងទាក់ទាញជនជាតិខ្មែរ ជាពិសេសយុវជនខ្មែរឲ្យជឿសាសនារបស់ខ្លួន អំណោយនោះពុំបរិសុទ្ធឡើយ ។ អំណោយណាដែលធ្វើទៅហើយចង់បានអ្វីមកវិញ ឈ្មោះថាដូរគ្នាឬឲ្យថ្លៃឈ្នួល ឬជាការទាក់ទាញទឹកចិត្ត ។ អំណោយដែលបរិសុទ្ធ គឺអំណោយដែលផ្តល់ទៅហើយគ្មានចង់បានមកវិញ គឺឲ្យដោយសេចក្តីសង្គ្រោះតែម្យ៉ាង ។ យ៉ាងណាមិញ គ្រិស្តសាសនាបានផ្តល់អំណោយ (ជារបៀបនុយសន្ទូចបញ្ឆោតត្រី) ដល់ជនជាតិខ្មែរឲ្យលះបង់ព្រះពុទ្ធសាសនា ហើយចូលកាន់សាសនារបស់ខ្លួនវិញ ជាអំណោយមានពិសពុល ឬទុកដូចជាកាំបិតសម្លាប់ព្រះពុទ្ធសាសនា ដែលជាព្រលឹងវិញ្ញាណរបស់ជនជាតិខ្មែរ, ទុកជាការរំលោភសិទ្ធិខាងជំនឿ ដែលមានចែងក្នុងច្បាប់ជាតិខ្មែរ និងច្បាប់អង្គការសហប្រជាជាតិ ជាពិសេសដូចជាការទាក់ទាញកុមារខ្មែរដែលជាយុវវ័យក្រោមអាយុ ឲ្យជឿសាសនាខ្លួន ជាការរំលោភដ៏ធ្ងន់ធ្ងរនូវសិទ្ធិកុមារ ។៚